# របាយការណ៍
# ស្តីពី
# សកម្មភាពការងារប្រចាំត្រីមាសទី១ ឆ្នាំ២០១០
# របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
# និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងត្រីមាសទី១ ឆ្នាំ២០១០ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដោយមានអគ្គលេខាធិការដ្ឋានជាអង្គភាពប្រតិបត្តិបានដំណើរការការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម :

## ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

### ក. ការងាររដ្ឋបាល

-អគ្គលេខាធិការធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បានដំណើរការងាររបស់ខ្លួនដោយក្នុងនោះអគ្គលេខាធិការដ្ឋានបានទទួលនូវលិខិតចូលចំនួន ៧៨លេខ ពីគ្រប់បណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល ម្ចាស់ជំនួយដៃគូអភិវឌ្ឍន៍ បណ្តាស្ថានទូតនានា និងជាពិសេសស្ថាប័នពាក់ព័ន្ធវិស័យតុលាការ

-ចំពោះលិខិតចេញវិញក្នុងកំឡុងត្រីមាសទី១ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បានផ្ញើលិខិតចេញបានចំនួនៈលិខិតស្នើផ្សេងៗចំនួន ២០លេខ លិខិតអញ្ជើញចូលរួមប្រជុំ ១០លេខ របាយការណ៍ និងកំណត់ហេតុបានចំនួន ៦លេខ ក្នុងនោះបានផ្ញើទៅក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល បណ្តាស្ថានទូត ដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធវិស័យតុលាការ

## ខ.ការពង្រឹងសមត្ថភាពរបស់អគ្គលេខាធិការដ្ឋាន និងការផ្សព្វផ្សាយកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-បានធ្វើការបណ្តុះបណ្តាលមន្ត្រីរបស់អគ្គលេខាធិការដ្ឋានៈ

-បានបញ្ជូនមន្ត្រីរបស់អគ្គលេខាធិការដ្ឋានចំនួន ០៩ រូបដើម្បីចូលរៀនវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសនៅសាលា (ELT) ដែលនឹងត្រូវបញ្ចប់នៅដំណាច់ខែមីនា ឆ្នាំ២០១០

-បានបញ្ជូនមន្ត្រី ០១រូប ដើម្បីចូលរៀនវគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់សម្រាប់ឆ្នាំ២០១០

-បានបញ្ជូនមន្ត្រី ០៤ រូប ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវិធីប្រើប្រាស់ (UNICODE) ដែលរៀបចំឡើងដោយ(NIDA)

-បានបោះពុម្ពចែកផ្សាយនូវព្រឹត្តប័ត្រកំណែទម្រង់ច្បាប់ និងតុលាការលេខ០៣ ឆ្នាំទី២ ផ្ញើជូនដល់គ្រប់ក្រសួងស្ថាប័ន អង្គការក្រៅរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ម្ចាស់ជំនួយ សាលាដំបូងរាជធានី-ខេត្ត និងបន្តរៀបចំបោះពុម្ពផ្សាយនូវព្រឹត្តប័ត្រលេខ០៤ របស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-ចូលរួមជាវាគ្មិនកិត្តិយសក្នុងកិច្ចសម្ភាសន៍របស់វិទ្យុអាស៊ីសេរី ទៅលើប្រធានបទៈកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅយប់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១០

-បានធ្វើសិក្ខាសាលានៅខេត្តព្រះសីហនុ រយៈពេលពីរថ្ងៃ ដើម្បីបន្តការធ្វើផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំ(២០០៩-២០១៣) និងផែនការការងាររបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌កាលពីថ្ងៃទី ០៣-០៥ ខែមីនា ឆ្នាំ២០១០

-រៀបចំធ្វើបច្ចុប្បន្នភាព គេហទំព័រក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

## គ. ការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ

-បានធ្វើការសិក្សាស្រាវជ្រាវវាយតម្លៃ និងរៀបចំសិក្ខាសាលាផ្សេងៗ ទាក់ទងដល់ការបញ្ចប់គម្រោងសិទ្ធិទទួលបានយុត្តិនៅកម្ពុជា (A2J)

-បានប្រជុំរវាងក្រសួងស្ថាប័នពាក់ព័ន្ធពិភាក្សាលើសំណើក្របខ័ណ្ឌនៃការអនុវត្តប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា

-បានបន្តប្រជុំពិភាក្សារៀបចំផែនការយុទ្ធសាស្ត្រ និងផែនការការងាររបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១០

-បានប្រជុំក្រុមការងារបច្ចេកទេសចម្រុះ (TWG)សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១០

-បានរៀបចំសិក្ខាសាលាពិនិត្យឡើងវិញនូវការអនុវត្ត កម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០ នៅសណ្ឋាគារអាំងទែកុងទីណង់តាល់ និងចុះធ្វើទំនាក់ទំនងតាមក្រសួងស្ថាប័នស្រង់ព័ត៌មានពាក់ព័ន្ធ

-បានប្រជុំរៀបចំសូចនាករតាមដានរួម (JMIs) ប្រចាំឆ្នាំ២០១០

-បានប្រជុំរៀបចំសៀវភៅកម្រងព័ត៌មានសេវាយុត្តិធម៌ ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធកាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១០

**គ. ផ្សេងៗ**

-ចូលរួមប្រជុំអន្តរក្រសួង

-ចូលរួមគ្រប់ក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

-ទទួលជួបជាមួយលោក (Lee Kiyoung) រដ្ឋអាជ្ញាក្រសួងយុត្តិធម៌ ដើម្បីស្វែងយល់ពីការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងតួនាទីរបស់ក្រសួងយុត្តិធម៌

-ចូលរួមសន្និសីទអន្តរជាតិ ស្តីពីកិច្ចសហប្រតិបត្តិការជាសាកល ដើម្បីជំរុញអភិបាលកិច្ចល្អនៅទីក្រុងណាហ្គូយ៉ា ប្រទេសជប៉ុនរយៈពេលបីថ្ងៃ ពីថ្ងៃទី២១ ដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០

-ចូលរួមធ្វើជាវាគ្មិនកិត្តិយសក្នុងសម្ភាសន៍របស់វិទ្យុអាស៊ីសេរី ទៅលើប្រធានបទៈ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កាលពីយប់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១០

-ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោមៈ១-សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ និង២-បញ្ហាផ្សេងៗ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១០

-ចូលរួមជាអធិបតីក្នុងពិធីសម្ពោធន៍ "សៀវភៅណែនាំពីការសម្រុះសម្រួល និងសៀវភៅណែនាំប្រតិបត្តិការសម្រាប់មណ្ឌលសេវាកម្មយុត្តិធម៌ស្រុក និងគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់" ដែលរៀបចំដោយស្រួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០ នៅសណ្ឋាគាសាន់វ៉េ ភ្នំពេញ។

-ចូលរួមសិក្ខាសាលា ស្តីពី"ការធីសម្ពោធឯកសារចងក្រងវិធានប្រពៃណីជនជាតិដើមភាគតិច" ដែលរៀបចំដោយគម្រោងសិទ្ធិទទួលបានយុត្តិធម៌ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១០ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។

-ចូលរួមសិក្ខាសាលាស្តីពីការបង្ហាញសមិទ្ធិផលនៃការអនុវត្តកម្មវិធី "ពង្រឹងសមត្ថភាព សន្ទនាសហគមន៍ "នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១០ នៅសណ្ឋាគារអ៊ីមភីរៀ

## ២-សន្និដ្ឋាន

ក្នុងខែត្រីមាសទី១ នៃឆ្នាំ២០១០ នេះអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានអនុវត្តការងារ និងបានផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើៈ ការរៀបចំនូវផែនការយុទ្ធសាស្ត្រ និងផែនការការងារសម្រាប់ការអនុវត្តភារកិច្ចរបស់ខ្លួន និងការពិនិត្យរៀបចំធ្វើបច្ចុប្បន្នកម្ម កម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌សម្រាប់ឆ្នាំ ២០០៩-២០១៣។

## ៣-ទិសដៅអនុវត្តបន្ត

-បញ្ចប់ការរៀបចំផែនការការងារសម្រាប់ផ្នែកផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន

-បញ្ចប់ការងារបច្ចុប្បន្នកម្មកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ បច្ចុប្បន្នកម្ម ២០១០-២០១៣

-បន្តការងាររៀបចំកម្រងសេវាព័ត៌មានទាក់ទងវិស័យដល់វិស័យយុត្តិធម៌

-បន្តពិនិត្យលើការបញ្ចប់គម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា

*រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០*

**អ្នកធ្វើរបាយការណ៍**

**បានឃើញ និងឯកភាព**

**អគ្គលេខាធិការរង**

ស៊ុន សីរីវុធ

**សួង លាងហៃ**